**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧០៩ ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០០៩



តង់របស់ប្រជាពលរដ្ឋជាង៥០០គ្រួសារដែលគ្មានឈ្មោះទទួលបានរបបផ្ទះ (រូបថត ចោមចៅ)

# ប្រជាពលរដ្ឋចំនួន៥៧៨គ្រួសារ ដែលរស់នៅក្រោមតង់ ត្រៀមសុំរដ្ឋាភិបាលទៅរស់នៅតាមតំបន់ព្រំដែនខ្មែរ_សៀម

រាជធានីភ្នំពេញ : ប្រជាពលរដ្ឋចំនួន៥៧៨គ្រួសារដែលរស់នៅក្រោមតង់យ៉ាងច្រើនស្មេកស្មុះ នៅខាងមុខបុរីសន្តិភាពរបស់ក្រុមហ៊ុន 7NG កំពុងរៀបចំគំរោងការធ្វើលិខិតស្នើសុំទៅរដ្ឋាភិបាល ដើម្បីបានទៅរស់នៅតំបន់ខ្សែបន្ទាត់ព្រំដែនកម្ពុជា-សៀម ដោយពួកគាត់អះអាងថាការរស់នៅក្រោមដំបូលតង់បែបនេះ គឺជាការរស់នៅបណ្ដោះអាសន្ន ឬមិនពិតប្រាកដប៉ុណ្ណោះ ។ លោកឡុង ដារ៉ា អាយុ៤០ឆ្នាំ ជាតំណាងប្រជាពលរដ្ឋខាងលើបានឱ្យដឹងថា ប្រជាពលរដ្ឋទាំង៥៧៨គ្រួសារ ដែលរស់នៅក្រោមតង់នាពេលនេះ កាលពីអតីតជាអ្នកមកពីបណ្ដាខេត្ត-ក្រុងនានាទូទាំងប្រទេសកម្ពុជា ហើយបានជួលផ្ទះគេស្នាក់នៅប្លុកប៊ូឌីញ ដីក្រហម ដើម្បីបានប្រកបរបររកស៊ីនៅភ្នំពេញ។ លុះក្រោយមកតំបន់ដីក្រហមនោះត្រូវអភិវឌ្ឍន៍ ហើយក្រុមហ៊ុន 7NG សហការជាមួយសាលារាជធានីភ្នំពេញ បានចេញគោលនយោបាយជាផ្ទះល្វែងដល់ម្ចាស់ផ្ទះពិតប្រាកដរាប់ពាន់គ្រួសាររួចមកហើយ ។ រីឯប្រជាពលរដ្ឋដែលជាអ្នកជួលផ្ទះគេស្នាក់នៅទាំង៥៧៨គ្រួសារនេះ មិនមានឈ្មោះក្នុងបញ្ជីហើយក៏គ្មានរបបផ្ទះសំរាប់រស់នៅដែរ ដូច្នេះទើបរស់នៅតែក្រោមតង់ជាបណ្ដោះអាសន្ន

រហូតដល់សព្វថ្ងៃដែលមានរយៈពេលជិត១ឆ្នាំ មកហើយ ។ តំណាងខាងលើបានបន្តថា ដោយសារការរស់នៅក្រោមដំបូលតង់ជួបការលំបាកយ៉ាងខ្លាំង ហើយមិនដឹងជារស់នៅបានដល់ពេលណា និងគួបផ្សំកាលពីពេលថ្មីៗនេះ ពួកគាត់បានឮប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជាមានប្រសាសន៍ថា ប្រជាពលរដ្ឋក្រីក្រពិតប្រាកដមានសិទ្ធិទៅរស់នៅព្រំដែន និងមានចែករបបដីនោះ ទើបពេលនេះពួកគាត់បានឯកភាពគ្នាចង់ទៅរស់នៅឯព្រំដែន ក្នុងគោលបំណងចង់បានការរស់នៅពិតប្រាកដមួយ ព្រមទាំងមានកន្លែងសំរាប់បង្កបង្កើនផលសំរាប់ចិញ្ចឹមជីវិត។ ប្រភពដដែលបានបន្តទៀតថា បន្ទាប់ពីមានការឯកភាពគ្នាហើយ ពួកគាត់បានជ្រើសរើសតំណាងចំនួន៤រូប ដើម្បីរៀបចំធ្វើលិខិតស្នើសុំទៅរាជរដ្ឋាភិបាលតាមរយៈសាលាសង្កាត់ចោមចៅ និងសុំឱ្យសាលាសង្កាត់បញ្ជូនលិខិតនោះដោយមានស្នាមមេដៃផង ទៅថ្នាក់លើជាបន្តបន្ទាប់រហូតដល់រាជរដ្ឋាភិបាលតែម្តង ។ ពួកគាត់មានសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលប្រាកដជាមានចិត្តសណ្តោសព្រោះការរស់នៅក្រោមតង់សព្វថ្ងៃនេះ កំពុងប្រឈមនឹងជំងឺផ្សេងៗទៀតផង ដោយសារតែរស់នៅក្នុងភក់ជ្រាំពោរពេញទៅដោយក្លិនស្អុយអាសោចិ៍ ។



ការរស់នៅក្នុងតំបន់បែបនេះធ្វើឱ្យចង់ចាកចេញពីដីក្រុង (រូបថត ចោមចៅ)

អាជ្ញាធរសង្កាត់ចោមចៅបានឱ្យដឹងថា ប្រជាពលរដ្ឋទាំងនោះពិតជាបានបោះតង់ និងសង់ខ្ទមតូចៗប្រជ្រៀតគ្នាយ៉ាងណែនណាន់តាន់តាប់នៅខាងមុខបុរីសន្តិភាពរបស់ក្រុមហ៊ុន 7NG នោះមែន។ មិនតែប៉ុណ្ណោះពេលថ្មីៗនេះមានតំណាងរបស់ពួកគាត់ទៅទំនាក់ទំនងសុំឱ្យអាជ្ញាធរសង្កាត់ ជួយបញ្ជូនលិខិតស្នើសុំទៅរាជរដ្ឋាភិបាល ដើម្បីទៅរស់នៅឯព្រំដែនកម្ពុជា-សៀមថែមទៀតផង។ ប៉ុន្តែទោះបីជាបែបណា អាជ្ញាធរសង្កាត់ពុំទាន់បានទទួលនូវលិខិតណាមួយច្បាស់លាស់ពីពួកគាត់នៅឡើយទេ ។ គាត់និយាយថា បើមានលិខិតមែន គាត់នឹងជួយបញ្ជូនទៅថ្នាក់លើបន្តបន្ទាប់មិនខាន ។